ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ២៨០ ព.ណ.ជ.ប.ព.-ប្រក

# ប្រកាស
## ស្តីពី
## ការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៧ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៣៤ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ស្តីពីការកំណត់ប្រភេទបែបបទ និងនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណដល់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការលើកលែង
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់បែបបទ ឯកសារតម្រូវក្នុងការផ្តល់ ការបន្តសុពលភាព ការធ្វើបច្ចុប្បន្នភាព និងការកែប្រែព័ត៌មាន លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីមានតម្លាភាព និងបង្កលក្ខណៈងាយស្រួលដល់ការស្នើសុំ និងផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

**ប្រការ២.-**

វាក្យសព្ទសំខាន់ៗ ដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យ ដូចខាងក្រោម៖

១- **លិខិតអនុញ្ញាត** សំដៅដល់លិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

២- **អាជ្ញាបណ្ណ** សំដៅដល់អាជ្ញាបណ្ណសម្រាប់ប្រតិបត្តិការផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

៣- **បុគ្គលស្នើសុំ** សំដៅដល់រូបវន្តបុគ្គល សហគ្រាសឯកបុគ្គល នីតិបុគ្គល និងសាខាក្រុមហ៊ុនបរទេស ដែលដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ។

៤- **មន្ត្រីត្រួតពិនិត្យ** សំដៅដល់មន្ត្រីរបស់ក្រសួងពាណិជ្ជកម្ម ដែលមានភារកិច្ចទទួល និងពិនិត្យពាក្យស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ។

៥- **បុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** សំដៅដល់បុគ្គលដែលប្រើប្រាស់មធ្យោបាយអេឡិចត្រូនិក ដើម្បីផ្គត់ផ្គង់ទំនិញ និង/ឬសេវា លើកលែងគ្រឹះស្ថានជានារ៉ាប់រង។

**ប្រការ៣.-**

បែបបទ និងនីតិវិធីនៃការស្នើសុំលិខិតអនុញ្ញាត ត្រូវបានកំណត់ដូចខាងក្រោម៖

១. រូបវន្តបុគ្គល សហគ្រាសឯកបុគ្គល ដែលនឹងប្រកបអាជីវកម្ម ធ្វើប្រតិបត្តិការ ឬសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ដោយត្រូវផ្តល់ព័ត៌មាន និងភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

**ក- សម្រាប់រូបវន្តបុគ្គល**

- លិខិតអនុញ្ញាតប្រកបអាជីវកម្មចេញដោយអង្គភាពច្រកចេញចូលតែមួយរាជធានី-ខេត្ត
- ប័ណ្ណប៉ាតង់ (ប្រសិនបើមាន)
- អត្តសញ្ញាណបណ្ណដែលនៅមានសុពលភាពរបស់បុគ្គលស្នើសុំ
- រូបថត ៤x៦ របស់រូបវន្តបុគ្គល ដែលថតមិនលើសពី៣ខែមុន
- មានគណនីនៅគ្រឹះស្ថានហិរញ្ញវត្ថុណាមួយ
- ឯកសារគំរូអាជីវកម្ម (Business Model) និងទម្រង់កិច្ចការពារអ្នកប្រើប្រាស់ សម្រាប់ការធ្វើពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក
- វិញ្ញាបនបត្រសេវាអនឡាញនិងឈ្មោះដែនពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍(ប្រសិនបើមាន)
- បុគ្គលស្នើសុំត្រូវបំពេញពាក្យស្នើសុំដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

**ខ- សម្រាប់សហគ្រាសឯកបុគ្គល**

- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ដែលមានកម្មវត្ថុអាជីវកម្មសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- ប័ណ្ណប៉ាតង់
- មានគណនីនៅគ្រឹះស្ថានហិរញ្ញវត្ថុណាមួយ
- ឯកសារគំរូអាជីវកម្ម (Business Model) និងទម្រង់កិច្ចការពារអ្នកប្រើប្រាស់ សម្រាប់ការធ្វើពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក
- វិញ្ញាបនបត្រសេវាអនឡាញ និងឈ្មោះដែនពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (ប្រសិនបើមាន)
- បុគ្គលស្នើសុំត្រូវបំពេញពាក្យស្នើសុំដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

២.បន្ទាប់ពីទទួលបានពាក្យស្នើសុំ មន្ត្រីត្រួតពិនិត្យត្រូវពិនិត្យលើភាពត្រឹមត្រូវនៃលក្ខខណ្ឌតម្រូវ ព័ត៌មាន និងឯកសារភ្ជាប់ដែលបានបំពេញ ហើយត្រូវឆ្លើយតបដល់បុគ្គលស្នើសុំ ក្នុងរយៈពេលយ៉ាងយូរ ៥(ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ។

**ប្រការ៤.-**

១.ត្រូវបានលើកលែងការតម្រូវឱ្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចំពោះរូបវន្តបុគ្គល ឬសហគ្រាសឯកបុគ្គលដែលធ្វើសកម្មភាពឬប្រតិបត្តិការ ដូចខាងក្រោម៖

ក-ការផ្សព្វផ្សាយពាណិជ្ជកម្មអំពីទំនិញ ឬសេវារបស់ខ្លួន រួមបញ្ចូលទាំងការផ្សព្វផ្សាយលក់ទំនិញឬសេវាដែលមិនមែនជាសំណើបង្កើតកិច្ចសន្យា។

ខ-ការបម្រុងទុកសេវាដែលមិនមានការកក់ប្រាក់ ឬទូទាត់កម្រៃ ដោយអតិថិជនឬអ្នកប្រើប្រាស់។

គ-ការលក់ទំនិញ ឬសេវារបស់រូបវន្តបុគ្គលឬសហគ្រាសឯកបុគ្គល ដែលមានផលរបប នៅក្រោមកម្រិតផលរបរជាអ្នកជាប់ពន្ធតូច។

ឃ-ការលក់ទំនិញ ឬសេវាដែលមានលក្ខណៈគ្រួសារ ឬតាមរដូវកាលប្រមូលផល។

ង-ការលក់ទំនិញ ឬសេវាដែលជាស្នាដៃសិល្បៈផ្ទាល់ខ្លួនសុទ្ធសាធ។

ច-ការបង្ហាត់បង្រៀនដោយឯកជនផ្ទាល់ខ្លួន។

ឆ-ការបង្ហាត់បង្រៀន ឬអប់រំអំពីសាសនារបស់រដ្ឋ។

ការបង្ហាត់បង្រៀនដោយសមាគមដែលមិនរកប្រាក់ចំណេញដោយផ្ទាល់ ឬប្រយោល និងសកម្មភាពប្រតិបត្តិការដោយស្ថាប័នរដ្ឋ ក្នុងការផ្តល់សេវាសាធារណៈក៏ត្រូវបានលើកលែងការតម្រូវឱ្យស្នើសុំលិខិតអនុញ្ញាតផងដែរ។

២.បុគ្គលស្នើសុំ ត្រូវជូនដំណឹងតាមរយៈគេហទំព័រ www.ecommercelicensing.moc.gov.kh ឬបញ្ជូនមកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ដែលមានព័ត៌មានដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ។

**ប្រការ៥.-**

១.នីតិបុគ្គល និងសាខាក្រុមហ៊ុនបរទេស ដែលនឹងប្រកបអាជីវកម្ម ធ្វើប្រតិបត្តិការ ឬសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ដោយត្រូវផ្តល់ព័ត៌មាន និងភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

ក- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ដែលមានកម្មវត្ថុអាជីវកម្មសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ខ- ប័ណ្ណប៉ាតង់

គ- វិញ្ញាបនបត្រសេវាអនឡាញ និងឈ្មោះដែនពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ឃ- ឯកសារអំពីមធ្យោបាយទូទាត់ប្រាក់ផ្តល់ ដោយបុគ្គលផ្តល់សេវាទូទាត់ ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា

ង- ឯកសារគំរូអាជីវកម្ម (Business Model) និងទម្រង់កិច្ចការពារអ្នកប្រើប្រាស់ សម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ច- គំរូកិច្ចសន្យារវាងអន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្ម អំពីការតម្រូវការព័ត៌មានអប្បបរមា (សម្រាប់អន្តរការី)

ឆ- បុគ្គលស្នើសុំត្រូវបំពេញព័ត៌មាន នៅក្នុងតារាងនៃពាក្យស្នើសុំដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៤ នៃប្រកាសនេះ។

២. បន្ទាប់ពីទទួលបានពាក្យស្នើសុំ មន្ត្រីត្រួតពិនិត្យត្រូវពិនិត្យលើភាពត្រឹមត្រូវនៃលក្ខខណ្ឌតម្រូវព័ត៌មាន និងឯកសារភ្ជាប់ដែលបានបំពេញ ហើយត្រូវឆ្លើយតបដល់បុគ្គលស្នើសុំក្នុងរយៈពេលយ៉ាងយូរ១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ។

**ប្រការ៦.-**

១. ក្នុងករណីព័ត៌មាន ឬឯកសារតម្រូវមិនគ្រប់គ្រាន់ និង/ឬមិនត្រឹមត្រូវ បុគ្គលស្នើសុំត្រូវធ្វើការកែតម្រូវ ឬផ្ដល់នូវព័ត៌មាន ឬឯកសារតម្រូវបន្ថែមក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានការជូនដំណឹងពីមន្ត្រីត្រួតពិនិត្យ។ រយៈពេលនៃការពិនិត្យ និងផ្ដល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ ត្រូវគិតចាប់ពីថ្ងៃដែលបុគ្គលស្នើសុំបានកែតម្រូវ ឬបំពេញបន្ថែមគ្រប់គ្រាន់។

២. ក្នុងករណីបុគ្គលស្នើសុំ បានដាក់ព័ត៌មានមិនពិត និង/ឬឯកសារក្លែងបន្លំ ឬខកខានមិនបានកែតម្រូវព័ត៌មាន ឬផ្ដល់ឯកសារតម្រូវបន្ថែម ក្នុងរយៈពេលដូចបានកំណត់ក្នុងកថាខណ្ឌទី១ មន្ត្រីត្រួតពិនិត្យអាចបដិសេធក្នុងការផ្ដល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណដល់បុគ្គលស្នើសុំ។

**ប្រការ៧.-**

លិខិតអនុញ្ញាត និងអាជ្ញាបណ្ណមានសុពលភាព ដូចខាងក្រោម៖

- លិខិតអនុញ្ញាតមានសុពលភាព ០២(ពីរ)ឆ្នាំ គិតចាប់ពីថ្ងៃផ្ដល់លិខិតអនុញ្ញាតដោយក្រសួងពាណិជ្ជកម្ម។
- អាជ្ញាបណ្ណមានសុពលភាព ០៣ (បី) ឆ្នាំ គិតចាប់ពីថ្ងៃផ្ដល់អាជ្ញាបណ្ណដោយក្រសួងពាណិជ្ជកម្ម។

**ប្រការ៨.-**

១- បុគ្គលស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ ត្រូវដាក់ពាក្យស្នើសុំមកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្មឱ្យបានយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនពេលអស់សុពលភាព។ ទម្រង់នៃពាក្យស្នើសុំបន្តលិខិតអនុញ្ញាតដូចភ្ជាប់ក្នុងឧបសម្ព័ន្ធទី៥.១ និងបន្តអាជ្ញាបណ្ណដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៥.២ នៃប្រកាសនេះ។

២- ក្នុងករណីបុគ្គលដែលបានទទួលលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណរួចហើយ តែខកខានមិនបានស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណដូចបានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើ នោះត្រូវបានចាត់ទុកថាបោះបង់ចោលលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ ហើយបុគ្គលនោះត្រូវដាក់ពាក្យស្នើលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណឡើងវិញ ដូចបានកំណត់ក្នុងប្រការ៣ និងប្រការ៥ ខាងលើ ក្រោយពេលអស់សុពលភាព។

**ប្រការ៩.-**

១- រូបវន្តបុគ្គល សហគ្រាសឯកបុគ្គល នីតិបុគ្គល ឬសាខាក្រុមហ៊ុនបរទេស ដែលបានផ្លាស់ប្ដូរ កែប្រែព័ត៌មាន ឬឯកសារក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ ក្រោយពេលធ្វើការកែប្រែ ត្រូវដាក់ពាក្យស្នើសុំប្ដូរលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណនៅក្រសួងពាណិជ្ជកម្ម ដូចខាងក្រោម៖

- ឈ្មោះ និងអាសយដ្ឋានអាជីវកម្ម សហគ្រាស ឬក្រុមហ៊ុន
- កម្មវត្ថុអាជីវកម្ម ឬគំរូអាជីវកម្ម (Business Model)
- វិញ្ញាបនបត្រសេវាអនឡាញ និងឈ្មោះដែន
- គំរូកិច្ចសន្យារវាងអន្តរការីនិងបុគ្គលផ្ដល់សេវាពាណិជ្ជកម្ម
- មធ្យោបាយអេឡិចត្រូនិកសម្រាប់ទំនាក់ទំនងជាមួយអតិថិជន។

ការស្នើសុំប្ដូរលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ ត្រូវបំពេញពាក្យស្នើសុំដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៦.១។

២- រាល់ការផ្លាស់ប្ដូរ ឬកែប្រែព័ត៌មាន ឬឯកសារភ្ជាប់ក្រៅពីចំណុចដែលបានចែងក្នុងកថាខណ្ឌទី១ខាងលើ រូបវន្តបុគ្គល សហគ្រាសឯកបុគ្គល នីតិបុគ្គល ឬសាខាក្រុមហ៊ុនបរទេស ត្រូវធ្វើបច្ចុប្បន្នភាពជូននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយពេលធ្វើការកែប្រែ តាមរយៈការបំពេញព័ត៌មាន និងឯកសារដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៦.២ ឬតាមរយៈគេហទំព័រ www.ecommercelicensing.moc.gov.kh។

**ប្រការ១០.-**

ក្នុងករណីដែលបុគ្គលបានទទួលលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណរួចហើយ មានបំណងផ្អាកជាបណ្ដោះអាសន្ននូវសកម្មភាព ឬបញ្ឈប់ប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវដាក់ពាក្យស្នើសុំ មកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ហើយត្រូវបំពេញពាក្យស្នើសុំដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៧។

**ប្រការ១១.-**

កម្រៃសេវាដែលត្រូវបង់ចូលជាថវិការដ្ឋ ត្រូវផ្អែកតាមការកំណត់ក្នុងប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ គ្រប់អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន គ្រប់ប្រធាននាយកដ្ឋាន គ្រប់ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៧រោច ខែ អស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ តុលា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន-សូរស័ក្តិ**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- រដ្ឋបាលរាជធានី ខេត្ត
- អគ្គនាយកដ្ឋានពន្ធដារ
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ